# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ៧៧៣ MoC / M 2002

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ជំរាបជូន**

- **អ្នកឧកញ៉ា ប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ**
- **ប្រធានសមាគមរោងចក្រកាត់ដេរ និងរោងចក្រស្បែកជើងនៅកម្ពុជា**
- **ប្រធានសមាព័ន្ធអភិវឌ្ឍន៍កសិកម្មនាំចេញកម្ពុជា**

**កម្មវត្ថុ** : សេចក្តីជូនដំណឹងអំពីការផ្តល់ប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម MFN របស់ប្រទេសចិន ដល់ ព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជូនដំណឹងដល់ អ្នកឧកញ៉ា លោកប្រធានសមាគមទាំងអស់អោយបានជ្រាបថា ដើម្បីពង្រីកការនាំចេញរបស់កម្ពុជា ក្រសួងពាណិជ្ជកម្ម បានខិតខំប្រឹងប្រែងតាមរយៈកិច្ចប្រជុំនានា ទាំងទ្វេរភាគី និងពហុភាគី ដើម្បីស្នើសុំការផ្តល់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្មពីប្រទេសចិន ។ នៅថ្ងៃទី២៦ កុម្ភៈ ឆ្នាំ២០០២ ស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន បានជូនដំណឹងជាផ្លូវការថា រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន បានយល់ព្រមផ្តល់ប្រព័ន្ធអនុគ្រោះ ពាណិជ្ជកម្ម MFN ដល់ប្រទេសកម្ពុជា ក្រោយពីប្រទេសចិនបានចូលជាសមាជិកអង្គកាពាណិជ្ជកម្មពិភពលោក ហើយបានចាប់ផ្តើមអនុវត្តច្បាប់ពន្ធនាំចេញនាំចូលថ្មី កាលពីថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០២ នេះតទៅ ។ នៅក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម MFN នេះ ការនាំចូលទំនិញពីប្រទេសកម្ពុជា នឹងត្រូវបង់ពន្ធតាមអាត្រា MFN ដែលជាអត្រាទាបជាងអត្រាធម្មតាសំរាប់ប្រទេសដែលមិនមែនជា សមាជិកអង្គការ ពាណិជ្ជកម្មពិភពលោក ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមអ្នកឧកញ៉ា លោកប្រធានសមាគមទាំងអស់ជ្រាបជាពត៌មាននិងមានវិធានការដើម្បីអនុវត្តជំរុញការនាំចេញរបស់ខ្លួនឱ្យបានកាន់តែប្រសើរឡើង ។

សូមអ្នកឧកញ៉ា លោកប្រធានសមាគម ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចំលងជូន

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានបច្ចេកទេស
- ឯកសារ- កាលប្បវត្តិ